UNITED NATIONS

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍យូភីអរ ជុំទី៣ របស់ប្រទេសកម្ពុជា ទាក់ទងនឹងសេរីភាពទទួលបានព័ត៌មាន

## តើដំណើរការពិនិត្យជាសកលតាមកាលកំណត់ ជាអ្វី?

ដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអ») គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលមានអាណត្តិពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ។ យន្តការ យូភីអ ជាដំណើរការដឹកនាំដោយរដ្ឋ ដែលរដ្ឋនីមួយៗប្រកាសអំពីវិធានការដែលរដ្ឋបានអនុវត្ត និងការបំពេញកាតព្វកិច្ចក្នុងការធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួនបានល្អប្រសើរ។ ប្រទេសកម្ពុជាត្រូវបានពិនិត្យដោយយន្តការ យូភីអ នេះ ក្នុងខែមករា ឆ្នាំ២០១៩ ដែលរដ្ឋសមាជិកបានផ្តល់អនុសាសន៍ចំនួន១៩៨ ហើយប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួន១៧៣ និងកត់សម្គាល់ចំនួន ២៥ អនុសាសន៍ ដោយមានការអនុម័តរបាយការណ៍លទ្ធផលនៃការពិនិត្យដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងកិច្ចប្រជុំលើកទី៤១ ក្នុងខែកក្កដា ឆ្នាំ២០១៩។ នៅក្នុងជុំទី៣ នេះ មានអនុសាសន៍កើនឡើង៦% បើប្រៀបធៀបទៅនឹងជុំទី២។

## ខាងក្រោមគឺជាអនុសាសន៍ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក៖

PRESS

១ ខិតខំប្រឹងប្រែងទ្វេដង ដើម្បីការពារសេរីភាពនៃគំនិត និងការបញ្ចេញមតិទាំងនៅលើប្រព័ន្ធអ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិត ដើម្បីធានានិងលើកកម្ពស់បរិយាកាសមួយប្រកបដោយសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្សនិងបក្សជំទាស់ ព្រមទាំងស៊ើបអង្កេតយ៉ាងមានប្រសិទ្ធភាព និងយ៉ាងហ្មត់ចត់ទៅលើ ករណីវាយប្រហារប្រឆាំងអ្នកទាំងនោះ។ (លីទុយអានី)

២ ធានានូវសេរីភាពបញ្ចេញមតិសម្រាប់ពលរដ្ឋ និងអ្នកសារព័ត៌មានទាំងអស់ រួមទាំង តាមអ៊ីនធឺណិត ដោយពិនិត្យមើលឡើងវិញទៅលើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកចុងក្រោយ ក៏ដូចជា ប្រកាសអន្តរក្រសួងកាលពីខែឧសភា ឆ្នាំ២០១៨ ដែលបានអនុញ្ញាតឱ្យមានការតាមឃ្លាំមើលមាតិកា/ខ្លឹមសារអត្ថបទតាមអ៊ីនធឺណិត។ (បារាំង)

៣ ធានាសេរីភាពបញ្ចេញមតិតាមអ៊ីនធឺណិត ដោយការលុបចោលការរឹតត្បិតហួសហេតុទៅលើសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដោយដកចេញសេចក្តីប្រកាសអន្តរក្រសួង (លេខ១៧០) ស្តីពីការត្រួតពិនិត្យការចេញផ្សាយរបស់គេហទំព័រ និងដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមតាមអ៊ីនធឺណិត។ (អាល្លឺម៉ង់ និងសហរដ្ឋអាម៉េរិក)

៤ កែសម្រួលការអនុម័ត និងការកែសម្រួលបទប្បញ្ញត្តិថ្មីៗនេះ ដែលរំលោភលើសេរីភាពបញ្ចេញមតិ និងសមាគម ដូចជា មានមូលដ្ឋានមិនច្បាស់លាស់និងទូលំទូលាយ សម្រាប់ការបង្ក្រាបការចេញផ្សាយនៅលើអ៊ីនធឺណិត នៅក្នុងប្រកាសស្តីពីការត្រួតពិនិត្យការចេញផ្សាយរបស់គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ (ស៊ុយអែត)

៥ ធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានស្របទៅតាមបទដ្ឋានអន្តរជាតិ នៃសេរីភាពបញ្ចេញមតិ និងសិទ្ធិជីវិតឯកជន។ (ស្វីស)

៦ ចាត់វិធានការដើម្បីការពារសេរីភាពបញ្ចេញមតិតាមក្នុង និងក្រៅប្រព័ន្ធអ៊ិនធឺណែត ក៏ដូចជាសេរីភាពខាងសមាគម និងការប្រមូលផ្តុំ។ (ប្រេស៊ីល)

## ចំណុចវឌ្ឍនភាព

ចាប់តាំងពីការទទួលយកអនុសាសន៍ រដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពលើចំណុចមួយចំនួនដូចខាងក្រោម៖

- ក្រសួងព័ត៌មានបានបង្កើតសេចក្តីព្រាងច្បាប់ស្តីពីការទទួលបានព័ត៌មានដោយមានការពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ ក្នុងនោះរួមទាំងអង្គការមិនមែនរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃបន្តទទួលយកការលើកឡើងនូវកង្វល់ សំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិលដើម្បីពិភាក្សាលើបញ្ហាពាក់ព័ន្ធ។

## ចំណុចត្រូវបន្តអនុវត្ត

ទោះបីជាទទួលបានវឌ្ឍនភាពមួយចំនួនក្តី តែរដ្ឋាភិបាលគួរបន្តអនុវត្តលើចំណុចមួយចំនួនទៀតដូចជា៖

- ធានានីតិវិធីបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការទទួលបានព័ត៌មានទៅកាន់ស្ថាប័នពាក់ព័ន្ធសម្រាប់ការអនុម័តបានរួចរាល់ជាស្ថាពរ។
- លើកកម្ពស់សិទ្ធិពលរដ្ឋក្នុងការទទួលបានសេវា និងអប់រំពួកគេអំពីនីតិរដ្ឋ និងលទ្ធភាពក្នុងការអនុវត្តសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋ។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ដើម្បីធានាដល់ការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិឯកជនបានរលូន។
- ធ្វើវិសោធនកម្មប្រកាសលេខ១៧០ ដើម្បីកាត់បន្ថយការរឹតត្បិតលើសេរីភាពអ៊ីនធឺណិតនិងបច្ចេកវិទ្យា។

ម.ស.ម.ក សូមរំឭកអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិបាលក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនិងស្នើឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងអស់ឱ្យបានមុនយូភីអជុំបន្ទាប់ ។ ម.ស.ម.ក សូមស្នើឱ្យរដ្ឋាភិបាលពិចារណាទទួលយកអនុសាសន៍ដែលកត់សម្គាល់ទាំងអស់នៅក្នុងជុំទីបួនផងដែរ៕



cc BY NC SA